# មនោជជាតក



## បុព្វនិទាន

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុអ្នកសេពគប់បក្ខពួកដែលយល់ខុសហើយ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យថា ចាបោ និន្នមតិ** ដូច្នេះជាដើម ។

## បច្ចុប្បន្ននិទាន

រឿងរ៉ាវបច្ចុប្បន្នមានសេចក្តីពិស្តារហើយ ក្នុង**មហិឡាមុខជាតក** ក្នុងកាលមុន ។ ប៉ុន្តែកាលនោះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុនោះ ក៏ជាអ្នកសេពគប់បក្ខពួកដែលយល់ខុសដែរ លុះទ្រង់ត្រាស់ដូច្នោះហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

## អតីតនិទាន

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វ ជារាជសីហ៍ឈ្មោល កាលនៅរួមនឹងរាជសីហ៍ញី បានកូន ២ គឺឈ្មោល ១ ញី ១ ។ កូនរាជសីហ៍ឈ្មោល ឈ្មោះ **មនោជៈ** កាលមនោជៈធំឡើងហើយ ទទួលយកកូនរាជសីហ៍ញីមួយ មកធ្វើជាប្រពន្ធ ។ ដូច្នោះ រាជសីហ៍ទាំងនោះ ទើបមានគ្នាដល់ទៅ ៥ ។ រាជសីហ៍មនោជៈ បានសម្លាប់ក្របីជាដើមក្នុងព្រៃនាំសាច់មកចិញ្ចឹមឪម៉ែប្អូនស្រី និងប្រពន្ធ ។ ថ្ងៃមួយវាឃើញឆ្កែចចកមួយឈ្មោះ គិរិយៈ នៅកន្ទៃងរកចំណី ដែលរត់គេចមិនទាន់បានដេកក្រាបចុះ ក៏សួរថា នែសម្លាញ់ សម្លាញ់ឯងធ្វើអ្វី ។ កាលចចកប្រាប់ថាបពិត្រលោកនាយ ខ្ញុំចង់នៅបម្រើលោក ។ រាជសីហ៍មនោជៈក៏យល់ព្រមហើយនាំចចកគិរិយៈមកកាន់គុហា ដែលជាលំនៅរបស់ខ្លួន ។ ព្រះពោធិសត្វឃើញហេតុនោះហើយ សូម្បីហាមថា នែកូនមនោជៈ ធម្មតាចចកទាំងឡាយជាសត្វទ្រុស្តសីល មានបាបធម៌ ប្រកបដោយអំពើដែលមិនមែនកិច្ច កូនឯងកុំយកចចកនោះ ទុកក្នុងសម្នាក់របស់ខ្លួនឲ្យសោះ ដូច្នេះហើយក៏មិនអាចនឹងហាមបាន ។

ថ្ងៃមួយ ចចកចង់ស៊ីសាច់សេះ ក៏និយាយនឹងមនោជៈថា បពិត្រនាយដែលឈ្មោះថា សាច់ដទៃ វៀរសាច់សេះចេញ ដែលពួកយើងមិនធ្លាប់ស៊ីមិនមាន ពួកយើងទៅចាប់សេះមួយមកស៊ីចុះ ។ មនោជៈសួរថា សេះមាននៅទីណា ។ ចចកប្រាប់ថា នៅឆ្នេរស្ទឹងក្រុងពារាណសី ។ មនោជៈទទួលពាក្យរបស់ចចកហើយទៅជាមួយចចកនោះ នៅពេលដែលសេះទាំងឡាយ នាំគ្នាងូតទឹកក្នុងស្ទឹង ក៏សង្រ្គុបចាប់បានសេះមួយ លើកឡើងដាក់ខ្នង នាំទៅកាន់មាត់គុហារបស់ខ្លួន ដោយកម្លាំងរាជសីហ៍ ។ ពេលរាជសីហ៍ដែលជាឪពុកខាំ

ស៊ីសាច់សេះហើយ ក៏និយាយថា នែកូន ធម្មតាសេះ ជាសត្វសម្រាប់ប្រើប្រាស់របស់ព្រះរាជាទាំងឡាយ ហើយព្រះរាជាទាំងឡាយ ក៏ទ្រង់មានមាយាច្រើន នឹងត្រាស់បញ្ជាពួកនាយខ្មាន់ធ្នូដ៏ស្ទាត់ជំនាញ, រាជសីហ៍ដែលស៊ីសាច់សេះនោះហើយ នឹងមានអាយុវែង រមែងមិនមាន ចាប់ពីពេលនេះទៅ កូនឯងកុំទៅចាប់សេះទៀត ។ មនោជៈមិនស្តាប់បង្គាប់តាមពាក្យទូន្មានប្រៀនប្រដៅរបស់ឪពុកឡើយ នៅតែចាប់សេះស៊ីដដែល ។ ព្រះរាជាទ្រង់ជ្រាបថា រាជសីហ៍ចាប់សេះស៊ី ក៏ទ្រង់បញ្ជាឲ្យសាងស្រះបោក្ខរណី សម្រាប់ឲ្យសេះនៅតែខាងក្នុងព្រះនគរ ។ សូម្បីធ្វើដូច្នោះហើយក៏ដោយ រាជសីហ៍នៅតែមកចាប់សេះស៊ីដដែល ។ ព្រះរាជាក៏ទ្រង់បញ្ជាឲ្យសាងរោងសេះ ហើយឲ្យស្មៅនិងទឹកដល់សេះក្នុងរោងនោះឯង ។ រាជសីហ៍ក៏ដើរលើកំផែងចាប់សេះក្នុងរោងនោះស៊ីទៀត ។

ព្រះរាជាក៏ទ្រង់បញ្ជាឲ្យហៅខ្មាន់ធ្នូដែលស្ទាត់ជំនាញក្នុងការបាញ់ធ្នូ គឺបាញ់មិនដាច់រយៈម្នាក់មក ហើយត្រាស់ថា ម្នាលអ្នកដ៏ចម្រើន អ្នកអាចបាញ់រាជសីហ៍បានទេ ។ គេក្រាបទូលថា បពិត្រមហារាជ ខ្ញុំព្រះអង្គអាច ។ ខ្មាន់ធ្នូឲ្យធ្វើប៉មទុកជិតកំផែង ជិតផ្លូវដើររបស់រាជសីហ៍ ហើយបានឈរនៅលើនោះ ។ រាជសីហ៍មកហើយ ឲ្យចចកឈរនៅខាងក្រៅព្រៃស្មសាន ហើយស្ទុះចូលព្រះនគរដើម្បីនឹងចាប់សេះ ។ ចំណែកនាយខ្មាន់ធ្នូ ពេលរាជសីហ៍មក ក៏គិតថា "រាជសីហ៍នេះ មានភាពរហ័សរហួនខ្លាំងណាស់" ដូច្នេះហើយទើបមិនបាញ់ ពេលរាជសីហ៍ចាប់សេះហើយដើរទៅ នាយខ្មាន់ធ្នូក៏បាញ់រាជសីហ៍បន្ថយនូវភាពរហ័ស ព្រោះភាវៈជាអ្នកមានភារៈធ្ងន់ ដោយកូនសរដែលស្រួចចំពីខាងក្រោយ ។ កូនសរធ្លុះចេញមកតាមកាយខាងមុខ ហើយរត់ទៅក្នុងអាកាស ។

រាជសីហ៍ស្រែកថា ខ្ញុំត្រូវគេបាញ់ហើយ ។ នាយខ្មាន់ធ្នូនោះបាញ់រាជសីហ៍នោះ ខ្សែបន្ទោះធ្នូលាន់ឮដូចផ្គើកបន្ទោរ ។ ចចកបានឮសំឡេងរាជសីហ៍ និងការបន្ទោះខ្សែធ្នូហើយគិតថា សម្លាញ់របស់យើង ត្រូវនាយខ្មាន់ធ្នូបាញ់ឲ្យងាប់ហើយដោយពិត ធម្មតាថា សេចក្តីស្និទ្ធស្នាលជាមួយនឹងសត្វទាំងឡាយដែលងាប់ហើយ រមែងមិនមាន ពេលនេះយើងនឹងទៅកាន់លំនៅរបស់ខ្លួនវិញ ។ កាលនឹងចរចាជាមួយខ្លួនឯងទើបពោលគាថា ២ គាថា ថា

**២៧៥ យថា ចាបោ និន្នមតិ ជិយា ចាបិ និកូជតិ**

**ហញ្ញតេ នូន មនោជោ មិគរាជា សខា មម ។**

ធ្នូទន់ខ្ទបទៅផង បន្ទោះលាន់ឮផង ដោយហេតុណា

មិគរាជ ឈ្មោះមនោជៈ ជាសម្លាញ់របស់អញ ត្រូវគេ

សម្លាប់ ដោយពិត ( ដោយហេតុនោះ ) ។

**២៧៦ ហន្ទ ទានិ វនន្តានិ បក្កមាមិ យថាសុខំ**

**នេតាទិសា សខា ហោន្តិ លព្ភា មេ ជីវ តោ សខា ។**

បើដូច្នោះមានតែ អញនឹងចៀសចេញទៅ កាន់ព្រៃជាទីពឹង

តាមសេចក្តីសប្បាយ ក្នុងពេលឥឡូវនេះ សត្វស្លាប់បែបនេះ

នឹងយកធ្វើជាសម្លាញ់ មិនកើត កាលបើអញរស់នៅ គង់

បានសម្លាញ់ទៀត ។

បណ្តាបទទាំងនោះ បទថា **យថា** សេចក្តីថា ធ្នូកោងដោយហេតុណា ។ បទថា **ហញ្ញតេ នូន** សេចក្តីថា ត្រូវសម្លាប់ហើយពិត ។

បទថា **នេតាទិសា** សេចក្តីថា ធម្មតាសត្វស្លាប់បែបនេះ នឹងធ្វើជាសម្លាញ់ មិនកើត ។ បទថា **លព្ភា មេ** សេចក្តីថា ឈ្មោះថាសម្លាញ់ កាលបើយើងនៅមានជីវិត អាចរកបានទៀត ។

ចំណែករាជសីហ៍រត់ទៅដោយរហ័សបំផុត រលាស់ឲ្យសេះធ្លាក់ត្រង់មាត់គុហា ហើយខ្លួនឯងក៏ដួលស្លាប់នៅទីនោះ ។ ពេលនោះ ញាតិរបស់វានាំគ្នាចេញទៅមើល បានឃើញវាប្រឡាក់ឈាម មានឈាមហូរចេញអំពីមុខរបួស ដែលត្រូវបាញ់ ដល់ការអស់ជីវិត ព្រោះសេពគប់មិត្តអាក្រក់ ។ មាតាបិតា ប្អូនស្រី និងប្រពន្ធរបស់មនោជៈបានឃើញហើយ ទើបពោលគាថា ៤ គាថាតាមលំដាប់ថា

**២៧៧ ន បាបជនសំសេវី អច្ចន្តំ សុខមេធតិ**
**មនោជំ បស្ស សេមានំ គិរិយស្សានុសាសនី ។**
បុគ្គលដែលសេពគប់ ជាមួយនឹងជនបាប មិនបានសេចក្តី
សុខដ៏ទៀងទាត់ឡើយ អ្នកចូរមើលសីហៈ ឈ្មោះ មនោជៈ
កំពុងដេក ( ស្លាប់នេះ ព្រោះតែជឿតាម ) ពាក្យប្រៀន
ប្រដៅ របស់ចចក ឈ្មោះ គិរិយៈ ។

**២៧៨ ន បាបសម្បវង្កេន មាតា បុត្តេន នន្ទតិ**
**មនោជំ បស្ស សេមានំ អច្ឆន្នំ សម្ហិ លោហិតេ ។**
មាតាមិនបានរីករាយ ជាមួយនឹងកូន ព្រោះតែគប់រក
សម្លាញ់អាក្រក់ អ្នកចូរមើលសីហៈ ឈ្មោះ មនោជៈ
ដេកត្រាំនៅក្នុងឈាមរបស់ខ្លួន ។

**២៧៩ ឯវមាបជ្ជតេ ពោសោ បាបិយោ ច និគច្ឆតិ**

**យោ វេ ហិតានំ វចនំ ន ករោតិ អត្ថទស្សិនំ ។**

*សត្វណា មិនធ្វើតាមពាក្យនៃជនទាំងឡាយ អ្នកប្រាថ្នានូវសេចក្តីចម្រើន អ្នកឃើញនូវប្រយោជន៍ ( ទៅក្នុងអនាគត ) សត្វនោះរមែងដល់ ( នូវសេចក្តីទុក្ខ ) យ៉ាងនេះផង តែងជួបប្រទះនូវទោសដ៏លាមកក្រៃលែងផង ។*

២៨០ **ឯវញ្ច សោ ហោតិ តតោ ច បាបិយោ**

**យោ ឧត្តមោ អធមជនូបសេវី**

**បស្សុត្តមំ អធមជនូបសេវិតំ**

**មិគាធិបំ សរវរវេគនិទ្ធុតំ ។**

*បុគ្គលដ៏ឧត្តមណា សេពគប់នឹងអធមជន ( ជនដ៏លាមក ) បុគ្គលនោះ អាក្រក់ក្រៃលែង ជាងអធមជននោះទៅទៀតយ៉ាងនេះ អ្នកចូរមើលនូវស្តេចម្រឹគដ៏ឧត្តម ដែលសេពគប់នឹងអធមជន ត្រូវកម្លាំងនៃព្រួញ ដ៏ប្រសើរ មុតហើយ ។*

*បណ្តាបទទាំងនោះ បទថា* **អច្ចន្តំ សុខមេធតិ** *សេចក្តីថា មិនបានសេចក្តីសុខរហូតអស់កាលយូរទេ ។*

*បទថា* **គិរិយស្សានុសាសនី** *សេចក្តីថា ព្រះពោធិសត្វ អ្នកជាបិតាពោលតិះដៀលថា នេះជាពាក្យប្រៀនប្រដៅរបស់ចចកឈ្មោះគិរិយៈ ។*

*បទថា* **បាបសម្បវង្កេន** *សេចក្តីថា មានសម្ញាញ់អាក្រក់ ដែលកោងក្នុងបាបទាំងឡាយ ។ បទថា* **អច្ចន្តំ** *បានដល់ លិចចុះ ។ បទថា* **បាបិយោ ច និគច្ឆតិ** *សេចក្តីថា នឹងជួបមិត្តអាក្រក់ ។ បទថា* **ហិតានំ** *សេចក្តីថា អ្នកប្រាថ្នានូវសេចក្តីចម្រើន ប្រាថ្នានូវប្រយោជន៍ ។ បទថា* **អត្ថទស្សិនំ** *សេចក្តី*

ថា អ្នកចង្អុលបង្ហាញនូវប្រយោជន៍អនាគត ។ បទថា **ចាបិយោ** បានដល់ អាក្រក់ជាង ថោកទាបជាង ។ បទថា **អជមជជ្ជូបសេវី** សេចក្ដីថា សេពគប់មនុស្សអាក្រក់ ។ បទថា **ឧត្តមំ** សេចក្ដីថា អ្នកប្រសើរបំផុត ដោយកម្លាំងកាយ ។

ព្រះមានព្រះភាគ បានត្រាស់អភិសម្ពុទ្ធគាថាចុងក្រោយបំផុត ថា

**២៨១ និហីយតិ បុរិសោ និហីនសេវី**

**ន ច ហាយេថ កទាចិ តុល្យសេវី**

**សេដ្ឋមុបគមំ ឧទេតិ ខិប្បំ**

**តស្មាត្តនោ ឧត្តរិតរំ ភជេថ ។**

បុរសអ្នកគប់រកនូវជនថោកទាប រមែងសាបសូន្យ បុគ្គលគប់រកនូវជនស្មើៗ គ្នា រមែងមិនសាបសូន្យ ក្នុងកាលណាឡើយ គប់រកនូវជនដែលប្រសើរជាង រមែងចម្រើន ឆាប់រួសរាន់ ព្រោះហេតុនោះ បុគ្គលគួរតែគប់រក នូវបុគ្គលដែលប្រសើរជាងខ្លួន ។

បណ្ដាបទទាំងនោះ បទថា **និហីយតិ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ធម្មតាថា បុគ្គលអ្នកសេពគប់ជនដ៏លាមក រមែងសាបសូន្យទៅគឺវិនាស បានដល់ ដល់នូវសេចក្ដីវិនាស ។ បទថា **តុល្យសេវី** សេចក្ដីថា បុគ្គលអ្នកសេពគប់មនុស្សស្មើនឹងខ្លួនដោយគុណទាំងឡាយ មានសីលជាដើម នឹងមិនសាបសូន្យ ។ ប៉ុន្តែគេនឹងមានសេចក្ដីចម្រើនតែម្យ៉ាង ។ បទថា **សេដ្ឋមុបគមំ** សេចក្ដីថា កាលចូលទៅសេពគប់បុគ្គលខ្ពង់ខ្ពស់ជាងខ្លួន ឬប្រសើរជាងខ្លួន

ដោយគុណទាំងឡាយមានសីលជាដើម ។ បទថា **ឧបេតិ ទិប្បំ** សេចក្តីថា នឹងចូលដល់គុណទាំងឡាយ មានសីលជាដើម ដោយឆាប់រហ័ស ។

ព្រះបរមសាស្តា លុះទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបប្រកាសសច្ចធម៌ទាំងឡាយ ហើយទ្រង់ប្រជុំជាតកទុក ក្នុងទីបំផុតនៃសច្ចៈ ភិក្ខុដែលសេពគប់បក្ខពួកដែលយល់ខុសនោះ បានសម្រេចសោតាបត្តិ-ផល ។ ចចកក្នុងកាលនោះ បានមកជាភិក្ខុទេវទត្ត, មនោជៈបានមកជាភិក្ខុអ្នកសេពគប់បក្ខពួកដែលយល់ខុស, ប្អូនស្រីបានមកជាឧប្បលវណ្ណាថេរី, ប្រពន្ធបានមកជាព្រះនាងខេមាភិក្ខុនី, មាតា បានបានមកជាមាតារបស់ព្រះរាហុល, ចំណែក រាជសីហបិតា គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា មនោជជាតក ទី ២ ។

សុត្តបិដក » ខុទ្ទកនិកាយ » ជាតកបាឡិ » **សត្តកនិបាតោ**

សុត្តបិដក (អដ្ឋកថា) » ខុទ្ទកនិកាយ (អដ្ឋកថា) » ជាតក-អដ្ឋកថា » **សត្តកនិបាតោ**